ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ROYAUME DU CAMBODGE
Nation Religion Roi

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTERE DE L'ECONOMIE ET DES FINANCES

No. ៩៧០ MEF/...........

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០១

# ប្រកាស
## ស្តីពី
## ការបំពេញបន្ថែមគណនីក្នុងប្លង់គណនេយ្យរដ្ឋ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន ស / រកត /១១៩៨ / ៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស / រកម / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស /៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីច្បាប់ប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១២០០/ ១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៤ អ.ន.ក្រ / បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ / បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៩ ប្រក.សហវ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីប្រព័ន្ធគណនីរបស់រតនាគារជាតិ
- បានឃើញកំណត់ផ្លាស់ប្តូរ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០០១ រវាងរាជរដ្ឋាភិបាលជប៉ុន និង រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់ជំនួយឥតចំណងដល់កម្ពុជាលើគំរោងទឹកប្រាក់ ២០០០ លានយ៉េន
- បានឃើញសេចក្តីត្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## សំរេច

**ប្រការ១** : ត្រូវបានបំពេញបន្ថែមនៅក្នុងប្រព័ន្ធគណនីនៃគណនេយ្យរបស់រដ្ឋ នូវគណនីដែលមានលេខសំគាល់ ៥៤២ មានឈ្មោះថា : " ប្រាក់បញ្ញើជំនួយជប៉ុន 5 " ។

គណនីនេះ ឆ្លុះបញ្ចាំងជាមួយគណនីប្រាក់បញ្ញើនៅធនាគារជាតិ ។ការកត់ត្រានៅរតនាគារជាតិ ដោយយោងតាមរបាយការណ៍របស់អង្គភាពគ្រប់គ្រងរូបិយប័ណ្ណក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ២** : គណនីលេខ ៥៤២ "ប្រាក់បញ្ញើជំនួយជប៉ុន 5" ត្រូវបានកត់ត្រា ÷

ខាងឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលបានមកពីហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល ជប៉ុនក្រោមរូបភាពជាជំនួយ រឺ ការខ្ចី

ខាងឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយតាមការសំរេចរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងក្របខ័ណ្ឌថវិកានិងអនុលោមតាមកម្មវិធីប្រើប្រាស់ដែលមានការយល់ព្រមពីរាជរដ្ឋាភិបាលជប៉ុន ។

សមតុល្យ ឥណទាយី : ឆ្លុះបញ្ចាំងនូវចំនួនទឹកប្រាក់បញ្ញើស្ដីពី ជំនួយជប៉ុន ៥ នៅធនាគារជាតិដែលពុំទាន់បានប្រើប្រាស់ ។

**ប្រការ៣** : អគ្គលេខាធិការ , ប្រធានខុទ្ទកាល័យ , ប្រធានរតនាគារជាតិ , ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច ,ប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ និង ប្រធានគ្រប់អង្គភាពពាក់ព័ន្ធមានភារកិច្ចអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៤** : ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល :**

- ទីស្ដីការគុណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប"
- ដូចប្រការ៤
  " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ